ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# គោលការណ៍ណែនាំ

# ស្តីពី

# ការឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាត

# សម្រាប់គ្រួសារក្រីក្រ

ឧបសម្ព័ន្ធនៃប្រកាសលេខ ០៥០ MISTI / ២០២១

ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

Ministry of Industry, Science, Technology & Innovation

លេខៈ ០៥០ MISTI / ២០២១

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការផ្តល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ១.-

ប្រកាសនេះ មានគោលបំណងដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការផ្តល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ ដើម្បីបង្កើនការទទួលបានទឹកស្អាតតាមប្រព័ន្ធបណ្តាញដល់គ្រួសារក្រីក្រ ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យទឹកស្អាត និងលើកកម្ពស់សុខុមាលភាពសាធារណៈ ជាពិសេសការកាត់បន្ថយភាពក្រីក្រ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

### ប្រការ២.-

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគម្រោងឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៣.-**

ការឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតនេះ ត្រូវផ្តល់ជូនតែចំពោះគ្រួសារក្រីក្រ ប្រភេទ ក្រ១ និងប្រភេទ ក្រ២ ដែលបានកំណត់ដោយក្រសួងផែនការ។

ការអនុវត្តគោលការណ៍ណែនាំស្តីពីការឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ ត្រូវឆ្លងកាត់ដំណាក់កាលៈ (១)ការដាក់ពាក្យស្នើសុំ (២)ការជ្រើសរើសទីតាំង (៣)ការប្រមូលព័ត៌មាន (៤)ការចុះកិច្ចព្រមព្រៀង (៥)ការភ្ជាប់បណ្តាញជូនគ្រួសារក្រីក្រ (៦)ការផ្ទៀងផ្ទាត់តំណគ្រួសារក្រីក្រដែលបានភ្ជាប់រួចរាល់ និង(៧)ការទូទាត់ថវិកា។

គ្រប់ដំណាក់កាលនីមួយៗ ត្រូវយកចិត្តទុកដាក់ និងចូលរួមទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធលើការអនុវត្តឱ្យមានតម្លាភាព និងប្រសិទ្ធភាព។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត
- សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com



## សាររបស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

*«ទឹកស្អាតសម្រាប់ទាំងអស់គ្នា»*

ដើម្បីលើកកម្ពស់សុខុមាលភាពនិងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន អ្នកដឹកនាំទូទាំងពិភពលោក ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) នៅឆ្នាំ២០១៥ ក្នុងនោះ គោលដៅលេខ៦.១ បានកំណត់ថា ត្រូវផ្គត់ផ្គង់ទឹកស្អាតដែលមានសុវត្ថិភាព និងថ្លៃសមរម្យសម្រាប់មនុស្សគ្រប់រូប ដែលកំណត់ថា "**ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានសាកលកម្ម និងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាព និងថ្លៃសមរម្យសម្រាប់ប្រជាជនទាំងអស់**" (CSDG)។

កាលពីឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយទឹកស្អាត និងអនាម័យ ដោយបាន លើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមវិនិយោគកសាងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត បង្កើនឱកាសឱ្យប្រជាពលរដ្ឋរស់នៅ តាមតំបន់ទីប្រជុំជន ទទួលបានសេវាទឹកស្អាតតាមបំពង់ប្រើប្រាស់។ នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល កម្ពុជានីតិកាលទី៦ នៃរដ្ឋសភាក៏បានកំណត់ពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង ទីប្រជុំជនឱ្យបាន ៩០% ដល់ឆ្នាំ២០២៣ និង១០០% ត្រឹមឆ្នាំ២០២៥ សម្រាប់បម្រើតម្រូវការចាំបាច់របស់ប្រជាជន ក៏ដូចសម្រាប់ ផលិតកម្ម និងសេវាកម្មនានាតាមរយៈការអភិវឌ្ឍពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ដោយឈរលើបុរេលក្ខខណ្ឌបួនយ៉ាងគឺ ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ"។

យោងតាមរបាយការណ៍សិក្សាសេដ្ឋកិច្ចសង្គមកម្ពុជានៅឆ្នាំ២០១៧ (CSES) មានគ្រួសារកម្ពុជាប្រមាណ ៦៥% ដែលមានលទ្ធភាពទទួលបានទឹកមានសុវត្ថិភាព (ដែលក្នុងនោះ ៩៨% នៅរាជធានីភ្នំពេញ ៧៩% នៅតាម តំបន់ទីប្រជុំជនដទៃទៀត និង៥៨%នៅទីជនបទ)។ រីឯការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់វិញ គឺនៅរាជធានីភ្នំពេញ បានប្រមាណ៩៦% ទីប្រជុំជននានាបានប្រមាណ៥៧% និងនៅជនបទប្រមាណ១៦%ប៉ុណ្ណោះ។

ក្នុងស្មារតីទទួលខុសត្រូវ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និង ទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនោះ ដើម្បីជំរុញលើវិស័យអាទិភាពទាំង៤ របស់រាជរដ្ឋាភិបាល ក្រសួង បានរៀបចំនិងអនុវត្តយ៉ាងសកម្មលើការងារផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាជនប្រើប្រាស់ និងបានរៀបចំនូវច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យទឹកស្អាត សម្រាប់ជួយដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំងសាធារណៈ និងឯកជន ឱ្យមានសមត្ថភាពដំណើរអាជីវកម្មនិងផ្គត់ផ្គង់ទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់ រាជរដ្ឋាភិបាលដូចមានចែងខាងលើ និងផ្តល់លទ្ធភាពជូនទឹកស្អាតប្រើប្រាស់នៅទីប្រជុំជនឆ្នាំ២០២៥ និងទូទាំង ប្រទេសតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

តាមការស្ទង់មតិដែលបានធ្វើឡើងជាមួយនឹងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននានា បានបង្ហាញថាជាទូទៅ គ្រួសារក្រីក្រ ដែលរស់នៅក្នុងតំបន់ដែលមានការផ្គត់ផ្គង់ទឹកស្អាត បានភ្ជាប់បណ្តាញទឹកស្អាតប្រើប្រាស់មានតែ ២០% ប៉ុណ្ណោះ *(Water Supply and Sanitation in Cambodia)*។ មូលហេតុដែលធ្វើឱ្យគ្រួសារក្រីក្រភ្ជាប់បណ្តាញ ទឹកស្អាតប្រើប្រាស់មានអត្រាទាបគឺកង្វះខាតលទ្ធភាពក្នុងការបង់ថ្លៃសិទ្ធិជាវទឹកស្អាត។

ថ្លៃសិទ្ធិជាវទឹកស្អាតជាទូទៅសម្រាប់ប្រភេទលំនៅដ្ឋានគឺប្រមាណ ២៩០ ០០០ រៀល (៧៥ដុល្លារអាមេរិក) *(ប្រកាសលេខ ៣២០ MISTI / ២០២០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០)* ខណៈដែលមានការសិក្សាជាច្រើនបាន

ប៉ាន់ស្មានថាគ្រួសារក្រីក្រមានលទ្ធភាពត្រឹមតែប្រមាណ ៨០ ០០០ រៀល (២០ដុល្លារអាមេរិក) ប៉ុណ្ណោះ សម្រាប់បង់ថ្លៃសិទ្ធិជាវទឹកស្អាត *(លទ្ធផលពីកម្មវិធី WASHOBA របស់អង្គការហ្គ្រេត)*។ ដូចនេះទាំងនៅទីប្រជុំជននិងជនបទ គ្រួសារក្រីក្រភាគច្រើនមិនមានលទ្ធភាពភ្ជាប់បណ្តាញទឹកស្អាត ពីប្រតិបត្តិករទឹកស្អាតសាធារណៈនិងឯកជននោះទេ ហើយពួកគេត្រូវជ្រើសរើសប្រភពទឹកប្រើប្រាស់ផ្សេងទៀត ដូចជាទឹកភ្លៀង ស្ទឹង ទន្លេ បឹងបួរ ស្រះ ត្រពាំង អណ្តូង ឬទិញពីអ្នកដឹកទឹកលក់ ជាទូទៅពុំមានគុណភាពធានាបាននូវសុវត្ថិភាព ជាហេតុធ្វើឱ្យគាត់ទទួលរងនូវផលប៉ះពាល់ដល់សុខភាព ខាតបង់ថវិកាសម្រាប់ព្យាបាលជំងឺ និងបាត់បង់ពេលវេលាក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត។

ផ្អែកតាមខ្លឹមសារខាងលើ និងឈរនៅលើជំហរជាអ្នកដឹកនាំនិងគ្រប់គ្រងវិស័យទឹកស្អាត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានធ្វើការដាក់ចេញនូវ **"គោលការណ៍ណែនាំស្តីពីការផ្តល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ"** ដើម្បីជាឯកសារមូលដ្ឋានមួយក្នុងការផ្តល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ។ កម្រងឯកសារនេះ បានរៀបរាប់អំពីលក្ខខណ្ឌ និងវិធីសាស្ត្រឧបត្ថម្ភធន ដោយបានភ្ជាប់មកជាមួយនូវការពណ៌នាលម្អិតអំពីដំណើរការអនុវត្តថវិកា និងទម្រង់ពាក្យស្នើសុំថវិកាឧបត្ថម្ភធន ជាឧបសម្ព័ន្ធ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា គោលការណ៍ណែនាំមួយនេះ នឹងត្រូវបានផ្សព្វផ្សាយ និងប្រើប្រាស់យ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធទាំងអស់នាពេលអនាគត។ គោលការណ៍ណែនាំនេះ ក៏ជាយន្តការឧបត្ថម្ភធន ដែលជាថាមពលមួយក្នុងការជួយបង្កើនការទទួលបានទឹកស្អាតតាមប្រព័ន្ធបណ្តាញទុយោដល់គ្រួសារក្រីក្រ ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ ជាពិសេសរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

ខ្ញុំគិតថា ភាគីពាក់ព័ន្ធនិងអ្នកប្រើប្រាស់ឯកសារនេះ នឹងទទួលបាននូវមេរៀន បទពិសោធន៍ ដែលជាធាតុចូលសំខាន់មួយក្នុងការផ្តល់មតិយោបល់កែលម្អបន្ថែម តាមការចាំបាច់នាពេលអនាគត។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ GRET និងក្រុមការងារពាក់ព័ន្ធ ក្នុងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីបង្កើតបានជាគោលការណ៍នេះឡើង និងសូមថ្លែងអំណរគុណផងដែរដល់ថ្នាក់ដឹកនាំមន្ត្រីអគ្គនាយកដ្ឋានទឹកស្អាត និងថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គ្រប់លំដាប់ថ្នាក់ ចំពោះការចូលរួមយ៉ាងសកម្មរបស់ឯកឧត្តម អស់លោក-លោកស្រី ក្នុងការបង្កើតគោលការណ៍ដ៏មានសារៈសំខាន់នេះ ដើម្បីបម្រើផលប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា។

ថ្ងៃ អង្គារ ៥ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

# មាតិកា


១. សេចក្តីផ្តើម ..... ១

២. គោលបំណង ..... ២

៣. លក្ខខណ្ឌទូទៅ ..... ២

៤. វិធីសាស្ត្រឧបត្ថម្ភធន ..... ៣

៤.១. អ្នកមានសិទ្ធិទទួលបានឧបត្ថម្ភធន ..... ៣

៤.២. សម្ភារតភ្ជាប់បណ្តាញទទួលបានការផ្តល់ឧបត្ថម្ភធន ..... ៣

៤.៣. ថវិកាឧបត្ថម្ភធន ..... ៣

៤.៤. ទីតាំងទទួលបានការផ្តល់ឧបត្ថម្ភធន ..... ៣

៤.៥. ការប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធ ..... ៤

៤.៦. ដំណើរការអនុវត្តថវិកាឧបត្ថម្ភធន ..... ៤

៥. ការតាមដានត្រួតពិនិត្យ និងវិសោធនកម្ម ..... ៥

ឧបសម្ព័ន្ធ ..... ៧

ឧបសម្ព័ន្ធ១៖ ការពណ៌នាលម្អិតអំពីដំណើរការអនុវត្តថវិកាឧបត្ថម្ភធន ..... ៧

ឧបសម្ព័ន្ធ២៖ ទម្រង់ពាក្យស្នើសុំថវិកាឧបត្ថម្ភធន ..... ៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

# គោលការណ៍ណែនាំស្ដីពីការផ្ដល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាតសម្រាប់គ្រួសារក្រីក្រ

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានបន្តអនុវត្តនូវកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដោយបានកំណត់វិស័យអាទិភាពចំនួន៤ គឺ៖ មនុស្ស ផ្លូវ ទឹក និងភ្លើង បានក្លាយជាវិស័យអាទិភាពបន្តបន្ទាប់ ដើម្បីជំរុញការអភិវឌ្ឍប្រទេស។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍនិងគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ប្រជាជនបានរួមចំណែកលើកកម្ពស់សុខុមាលភាព និងកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខណ្ឌគោលដៅអភិវឌ្ឍវិស័យទឹកស្អាត ដើម្បីជំរុញឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពដែលកំណត់ថា ***«ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានសាកលកម្ម និងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាព និងថ្លៃសមរម្យសម្រាប់ប្រជាជនទាំងអស់» (CSDG)***។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយសម្រេចឱ្យបាននូវសមិទ្ធផលនៃការធ្វើកំណែទម្រង់ដើម្បីអភិវឌ្ឍវិស័យទឹកស្អាតឱ្យកាន់តែល្អប្រសើរឡើង ដោយបង្កើននូវសមត្ថភាពផលិត និងពង្រីកវិសាលភាពសេវាកម្មផ្គត់ផ្គង់ទឹកស្អាតឱ្យកាន់តែទូលាយ ដោយឈរលើគោលការណ៍បុរេលក្ខខណ្ឌ ៤យ៉ាងគឺ ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។

ការផ្គត់ផ្គង់ទឹកស្អាតតាមបណ្ដាញ គឺជាមធ្យោបាយតែមួយគត់ដែលមានសុវត្ថិភាព និងនិរន្តភាពក្នុងការទទួលបានទឹកស្អាតសម្រាប់អ្នកប្រើប្រាស់។ តាមការប៉ាន់ស្មាន ប្រមាណជា ៦០% នៃប្រជាជនក្រីក្រ និង ៩៥% នៃអ្នកដែលមានជីវភាពធូរធារ ទទួលបានសេវាទឹកដែលមានការសម្អាតសម្រាប់ប្រើប្រាស់(JMP ឆ្នាំ២០១៧)។ កត្តារាំងស្ទះចម្បងគឺកង្វះខាតលទ្ធភាពបង់ថ្លៃសិទ្ធិជាវទឹកស្អាត។ ការស្ទង់មតិមួយដែលបានធ្វើឡើងជាមួយនឹងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននានាបានបង្ហាញថា ជាទូទៅគ្រួសារក្រីក្រចំនួនត្រឹមតែ ២០% ដែលរស់នៅតំបន់ដែលគ្របដណ្ដប់ដោយបណ្ដាញ

ផ្គត់ផ្គង់ទឹកស្អាតបានភ្ជាប់ទឹកស្អាតប្រើប្រាស់។ មូលហេតុមួយក្នុងចំណោមហេតុផលសំខាន់ផ្សេងៗទៀតដែលធ្វើឱ្យការភ្ជាប់បណ្តាញមានអត្រាទាប គឺលទ្ធភាពទូទាត់ថ្លៃសិទ្ធិជាវទឹកស្អាតដើម្បីភ្ជាប់បណ្តាញចូលផ្ទះរបស់ប្រជាពលរដ្ឋក្រីក្រ[1]។

ថ្លៃសិទ្ធិជាវទឹកស្អាតជាទូទៅសម្រាប់ប្រភេទលំនៅដ្ឋានគឺប្រមាណ ២៩០ ០០០ រៀល (៧៥ដុល្លារអាមេរិក) ខណៈដែលមានការសិក្សាជាច្រើនបានប៉ាន់ស្មានថាគ្រួសារក្រីក្រមានលទ្ធភាពប្រមាណ ៨០ ០០០ រៀល (២០ដុល្លារអាមេរិក) ប៉ុណ្ណោះសម្រាប់បង់ថ្លៃសិទ្ធិជាវទឹកស្អាត[2]។ ដូច្នេះទាំងនៅទីប្រជុំជន និងជនបទ គ្រួសារក្រីក្រភាគច្រើនមិនមានលទ្ធភាពភ្ជាប់បណ្តាញទឹកស្អាតពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជននោះទេ ហើយពួកគេបានជ្រើសរើសប្រើប្រាស់ប្រភពទឹកផ្សេងៗ ដូចជាទឹកអណ្តូង ទឹកលើដី ឬទិញពីអ្នកដឹកទឹកលក់ ដែលជាទូទៅពុំមានគុណភាពសមស្រប ជាហេតុធ្វើឱ្យពួកគាត់ត្រូវទទួលនូវផលប៉ះពាល់ដល់សុខភាព ខាតបង់ថវិកាសម្រាប់ព្យាបាលជំងឺ និងបាត់បង់ពេលវេលាក្នុងការប្រកបរបរចិញ្ចឹមជីវិត។

## ២. គោលបំណង

គោលការណ៍ណែនាំនេះ មានគោលបំណងផ្តល់នូវយន្តការឧបត្ថម្ភធន ដែលមានលក្ខណៈសមស្របក្នុងការជួយបង្កើនការទទួលបានទឹកស្អាតតាមប្រព័ន្ធបណ្តាញដល់គ្រួសារក្រីក្រ ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ ជាពិសេសការកាត់បន្ថយភាពក្រីក្រ។

## ៣. លក្ខខណ្ឌទូទៅ

ដើម្បីឱ្យការអនុវត្តឧបត្ថម្ភធនដំណើរការទៅប្រកបដោយប្រសិទ្ធភាព ការផ្តល់ឧបត្ថម្ភធនគួរគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

(១) ពិនិត្យលើស្ថានភាពជាក់ស្តែង និងតម្រូវការរបស់អ្នកប្រើប្រាស់
(២) កំណត់គោលដៅសម្រាប់គ្រួសារដែលក្រីក្រ
(៣) កំណត់យ៉ាងច្បាស់ពីលក្ខណៈវិនិច្ឆ័យក្នុងការមានសិទ្ធិទទួលបានថវិកាឧបត្ថម្ភធន
(៤) មានតម្លាភាព
(៥) មានភាពងាយស្រួលក្នុងការគ្រប់គ្រង
(៦) ងាយស្រួលតាមដានត្រួតពិនិត្យ
(៧) មិនមែនជាអន្តរាគមន៍ដាច់ដោយឡែក។

ការអនុវត្តថវិកាឧបត្ថម្ភធននេះនឹងមិនរាំងស្ទះដល់ទីផ្សារដែលមានសក្តានុពលស្រាប់ មិនបង្កលទ្ធភាពផ្នែកហិរញ្ញវត្ថុ មិនបង្កភាពរាំងស្ទះដល់ការច្នៃប្រឌិតថ្មី ដោយរង់ចាំតែការផ្តល់ឧបត្ថម្ភធន និងផ្តល់លទ្ធភាពតភ្ជាប់បណ្តាញទឹកស្អាតនៅតំបន់ដែលមានតម្រូវការទីផ្សារទាប។

---

[1] Water Supply and Sanitation in Cambodia: Turning Finance into Services for the Future ខែឧសភា ឆ្នាំ២០១៥ ទំព័រទី ៣០។

[2] លទ្ធផលពីកម្មវិធី WASHOBA របស់អង្គការហ្គ្រេត

## ៤. វិធីសាស្ត្រឧបត្ថម្ភធន

### ៤.១. អ្នកមានសិទ្ធិទទួលបានឧបត្ថម្ភធន

គ្រួសារដែលមានសិទ្ធិទទួលបានការផ្តល់ឧបត្ថម្ភធនសម្រាប់ថ្លៃសិទ្ធិជាវទឹកស្អាត គឺជាគ្រួសារក្រីក្រដែលបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រប្រភេទ ក្រ១ និង ក្រ២ ដោយក្រសួងផែនការ និងជាគ្រួសារដែលមិនទាន់បានតភ្ជាប់បណ្តាញទឹកស្អាតប្រើប្រាស់។

### ៤.២. សម្ភារតភ្ជាប់បណ្តាញទទួលបានការផ្តល់ឧបត្ថម្ភធន

សម្ភារសម្រាប់តភ្ជាប់បណ្តាញត្រូវគោរពតាមស្តង់ដា អនុវត្តតាមបទដ្ឋានបច្ចេកទេសអប្បបរមា និងបទប្បញ្ញត្តិនានារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សម្ភារទាំងអស់នោះ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ក្នុងកិច្ចសន្យាជាមួយអតិថិជន និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

### ៤.៣. ថវិកាឧបត្ថម្ភធន

ថ្លៃសិទ្ធិជាវទឹកមានភាពខុសៗគ្នា អាស្រ័យលើទំហំនាឡិកាទឹក និងប្រវែងបណ្តាញចូលផ្ទះដែលត្រូវប្រើ។ ជាទូទៅ ថ្លៃសិទ្ធិជាវទឹកគឺប្រមាណ ២៩០ ០០០ រៀល (៧៥ដុល្លារអាមេរិក) សម្រាប់តំណប្រើប្រាស់លក្ខណៈគ្រួសារដែលមានចម្ងាយមិនលើសពី ៥០ម៉ែត្រ ពីបណ្តាញចែកចាយរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ យោងតាមកាតព្វកិច្ចរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដែលមានចែងក្នុងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត មានភារកិច្ចភ្ជាប់បណ្តាញទឹកស្អាតដល់អ្នកប្រើប្រាស់ ស្របតាមប្រកាសលេខ ៣២០ MISTI / ២០២០ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០។

ដើម្បីធានាបាននូវលទ្ធភាពសមរម្យ គ្រួសារក្រីក្រត្រូវចូលរួមបដិភាគ ២០% នៃថ្លៃសិទ្ធិជាវទឹកស្អាត ប៉ុន្តែមិនលើសពី ៨០ ០០០ រៀល (២០ដុល្លារអាមេរិក) ហើយនៅសល់ពីនោះគឺជាថវិកាឧបត្ថម្ភធនពីគម្រោង។ ថ្លៃសិទ្ធិជាវទឹកស្អាត ត្រូវអនុវត្តតាមតារាងថ្លៃសិទ្ធជាវទឹក ដែលបានកំណត់ក្នុងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលក្រសួងបានផ្តល់ជូន ឬតាមថ្លៃជាក់ស្តែងដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតកំពុងអនុវត្តដែលមិនលើសពីការកំណត់របស់ក្រសួង។ គ្រួសារដែលទទួលបានការផ្តល់ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកស្អាត មានកាតព្វកិច្ចបង់ថ្លៃសេវាផ្សេងៗតាមការកំណត់នៃប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលក្រសួងបានផ្តល់ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងថ្លៃទឹកស្អាតដែលបានប្រើប្រាស់ជាក់ស្តែងតាមខែនីមួយៗ។

សម្រាប់បណ្តុំគ្រួសារក្រីក្រដែលមានផ្ទះនៅឆ្ងាយលើស ៥០ម៉ែត្រ ពីបណ្តាញទុយោចែកចាយ អ្នកអនុវត្តគម្រោងអាចពិនិត្យមើលលទ្ធភាពឧបត្ថម្ភធនតាមវិធីសាស្ត្រផ្សេងៗទៀត ដែលអាចតម្រូវឱ្យមានការពង្រីកបណ្តាញចែកចាយ។

### ៤.៤. ទីតាំងទទួលបានការផ្តល់ឧបត្ថម្ភធន

ថវិកាឧបត្ថម្ភធនលើថ្លៃសិទ្ធិជាវទឹកស្អាត នឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋក្រីក្រដែលរស់នៅក្នុងភូមិ ឃុំ/សង្កាត់ដែលជាតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលទទួលបានប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងអតីតក្រសួងឧស្សាហកម្ម និងសិប្បកម្ម (លើកលែងរដ្ឋាករទឹកស្វយ័ត)។ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ត្រូវដាក់ពាក្យស្នើសុំថវិកាឧបត្ថម្ភធននេះដោយមានការឯកភាពពីមេឃុំ/ចៅសង្កាត់។

ភាគីពាក់ព័ន្ធដែលត្រូវចូលរួមធ្វើការវាយតម្លៃពាក្យស្នើសុំ និងអនុម័តលើការជ្រើសរើសទីតាំងសម្រាប់ការអនុវត្តគម្រោងរួមមាន៖

- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត (ឧ.វ.ប.ន)

- សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)
- ដៃគូអភិវឌ្ឍន៍/ម្ចាស់ជំនួយពាក់ព័ន្ធដែលផ្តល់ថវិកាឧបត្ថម្ភធន។

**សូចនាករដើម្បីវាយតម្លៃពាក្យស្នើសុំមាន៖**

- ឆន្ទៈរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងការតភ្ជាប់បណ្តាញទឹកស្អាតដល់គ្រួសារក្រីក្រ
- វិសាលភាពតំបន់សេវាកម្មបច្ចុប្បន្ន
- ចំនួនគ្រួសារក្រីក្រមានលក្ខណសម្បត្តិទទួលបានឧបត្ថម្ភធន
- សមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- គុណភាពទឹករបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត
- គុណភាពសេវារបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត
- លក្ខខណ្ឌផ្សេងៗរបស់ម្ចាស់ជំនួយ។

ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយអំពីគោលការណ៍ឧបត្ថម្ភធន ដើម្បីជំរុញ និងលើកទឹកចិត្តគ្រួសារក្រីក្របានតភ្ជាប់បណ្តាញទឹកស្អាត។ ការភ្ជាប់បណ្តាញគឺត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត។

## ៤.៥. ការប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធ

មុនពេលចាប់ផ្តើមអនុវត្តគម្រោង ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាធរមូលដ្ឋាន(ឃុំ/សង្កាត់ និង/ឬ ភូមិ) ត្រូវចូលរួមប្រមូលទិន្នន័យ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យពីមន្ទីរពាក់ព័ន្ធ ដើម្បីមានលទ្ធភាពបញ្ជាក់ ត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាព និងតម្លាភាពក្នុងការអនុវត្តគម្រោង។

ទិន្នន័យទាំងនោះមានដូចជា៖

- ចំនួន និងឈ្មោះភូមិសរុបដែលស្ថិតក្នុងប្រកាសអនុញ្ញាត
- ចំនួន និងឈ្មោះភូមិដែលបានដាក់បណ្តាញរួចហើយ
- ចំនួនគ្រួសារសរុបក្នុងភូមិ
- ចំនួនតំណអតិថិជនសរុបតាមភូមិនីមួយៗ
- ចំនួនតំណគ្រួសារក្រីក្រសរុប និងទីតាំងរបស់គ្រួសារក្រីក្រ
- ប្រភពទឹក សមត្ថភាពផលិត គុណភាពទឹក គុណភាពសេវា តម្រូវការទឹក
- ប្រវែងទុយោសរុបដែលបានដាក់
- ប្រវែង និងទំហំទុយោសរុបដែលត្រូវដាក់បន្ថែម ដើម្បីឱ្យអាចភ្ជាប់ជូនគ្រួសារក្រីក្របាន។

## ៤.៦. ដំណើរការអនុវត្តថវិកាឧបត្ថម្ភធន

ដើម្បីឱ្យការអនុវត្តថវិកាឧបត្ថម្ភធនមានតម្លាភាព និងការយោគយល់គ្នា ត្រូវមានការព្រមព្រៀង និងមានការពិភាក្សាជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ ការអនុវត្តថវិកាឧបត្ថម្ភធនត្រូវមានកិច្ចព្រមព្រៀងសហប្រតិបត្តិការដោយឡែកៗ ដោយមានចុះហត្ថលេខារវាងម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងមានការឯកភាពដោយមេឃុំ/ចៅសង្កាត់។ ដំណើរការអនុវត្តថវិកាឧបត្ថម្ភធនត្រូវ អនុវត្តតាមដំណាក់កាលដូចខាងក្រោម៖

**រូបភាពទី១៖ ដំណាក់កាលនៃការអនុវត្តថវិកាឧបត្ថម្ភធន (លម្អិតក្នុងឧបសម្ព័ន្ធ១)**




ការអនុវត្តគោលការណ៍ត្រូវមានភាពច្បាស់លាស់ និងងាយយល់សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត អាជ្ញាធរមូលដ្ឋាន និងគ្រួសារក្រីក្រផ្ទាល់។ ការអនុវត្តគោលការណ៍នេះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីធានានូវភាពស្មើគ្នា ហើយចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃទិន្នន័យមូលដ្ឋាន សំដៅជៀសវាងការប្រើប្រាស់ថវិកាឧបត្ថម្ភធនខុសគោលដៅ។

## ៥. ការតាមដានត្រួតពិនិត្យ និងវិសោធនកម្ម

សូចនាករដែលត្រូវតាមដានត្រួតពិនិត្យ រួមមាន ៖

- ចំនួនគ្រួសារក្រីក្រដែលបានតភ្ជាប់បណ្តាញទឹកស្អាតថ្មីបន្ទាប់ពីបានអនុវត្តគោលការណ៍ណែនាំ
- គុណភាពទឹកស្អាត
- វាយតម្លៃផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត
- ការចាប់អារម្មណ៍របស់គ្រួសារក្រីក្រក្រោយពីទទួលបានការផ្គត់ផ្គង់ទឹកស្អាត។

ដើម្បីឱ្យយន្តការឧបត្ថម្ភធនដល់គ្រួសារក្រីក្រកាន់តែមានប្រសិទ្ធភាព ធានាបាននូវតម្លាភាព និងភាពស្មើគ្នា ការធ្វើវិសោធនកម្មអាចធ្វើឡើងនៅពេលចាំបាច់ណាមួយ ដោយក្រុមការងាររបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ ការពណ៌នាលម្អិតអំពីដំណើរការអនុវត្តថវិកាឧបត្ថម្ភធន

<table>
<tr><th colspan="2">ពណ៌នា</th><th>អ្នកទទួលខុសត្រូវ</th><th>ចូលរួម/គាំទ្រដោយ</th></tr>
<tr><td>ដំណាក់កាលទី១</td><td>ពាក្យស្នើសុំ</td><td>ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងមេឃុំ/ចៅសង្កាត់</td><td>ភ្នាក់ងារអនុវត្តគម្រោង</td></tr>
<tr><td colspan="4">ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសហការជាមួយនឹងមេឃុំ/ចៅសង្កាត់ ដាក់ពាក្យស្នើថវិកាឧបត្ថម្ភធនលើថ្លៃសិទ្ធជាវទឹកស្អាតដល់គ្រួសារក្រីក្រ ដោយបំពេញនូវព័ត៌មានផ្សេងៗក្នុងទម្រង់ពាក្យស្នើសុំ (ឧបសម្ព័ន្ធ២) ដែលមានការណែនាំដោយគម្រោង និងចុះហត្ថលេខាដោយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងមានការឯកភាពពីមេឃុំ/ចៅសង្កាត់ក្នុងតំបន់សេវាកម្មដែលបានស្នើសុំ។</td></tr>
<tr><td>ដំណាក់កាលទី២</td><td>ការជ្រើសរើសទីតាំង</td><td>មន្ទីរ ឧ.រ.ប.ន រាជធានី ខេត្ត ម្ចាស់ជំនួយ និងស.ទ.ក</td><td>ភ្នាក់ងារអនុវត្តគម្រោង</td></tr>
<tr><td colspan="4">ការជ្រើសរើសទីតាំងផ្តល់ថវិកាឧបត្ថម្ភធន ត្រូវមានការចូលរួមពីមន្ទីរ ឧ.រ.ប.ន រាជធានី ខេត្ត ម្ចាស់ជំនួយ និងស.ទ.ក ដើម្បីពិនិត្យលើព័ត៌មានក្នុងពាក្យស្នើសុំរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដោយផ្អែកលើសូចនាករសំខាន់ដូចខាងក្រោម៖<br>- វិសាលភាពតំបន់សេវាកម្មបច្ចុប្បន្ន<br>- ចំនួនគ្រួសារក្រីក្រមានលក្ខណសម្បត្តិទទួលបានការផ្តល់ឧបត្ថម្ភធន<br>- សមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត<br>- ឆន្ទៈរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងការតភ្ជាប់បណ្តាញទឹកស្អាតដល់គ្រួសារក្រីក្រ<br>- គុណភាពទឹករបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត<br>- គុណភាពសេវារបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត<br>- លក្ខខណ្ឌផ្សេងៗរបស់ម្ចាស់ជំនួយ។</td></tr>
<tr><td>ដំណាក់កាលទី៣</td><td>ការចុះប្រមូលព័ត៌មាន</td><td>ម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង</td><td>-</td></tr>
<tr><td colspan="4">ម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោងត្រូវចុះប្រមូលទិន្នន័យបន្ថែមដែលចាំបាច់សម្រាប់ការវាយតម្លៃ និងកែលម្អសមត្ថភាពផ្គត់ផ្គង់ គុណភាពទឹក គុណភាពសេវាកម្ម និងកំណត់ចំនួនគ្រួសារក្រីក្រមានលក្ខណសម្បត្តិទទួលបានថវិកាឧបត្ថម្ភធន ដោយមានការសហការជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាធរមូលដ្ឋាន។ បញ្ជីឈ្មោះគ្រួសារក្រីក្រដែលមានលក្ខណសម្បត្តិទទួលបានឧបត្ថម្ភធន និងផ្តល់ឱ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដើម្បីផ្ទៀងផ្ទាត់ និងធ្វើការភ្ជាប់បណ្តាញដល់គ្រួសារក្រីក្រ ដើម្បីធានាបាននូវប្រសិទ្ធភាព និងតម្លាភាពនៃការផ្តល់ឧបត្ថម្ភធន។</td></tr>
</table>

<table>
<tr><td>ដំណាក់កាលទី៤</td><td>កិច្ចព្រមព្រៀងសហប្រតិបត្តិការ</td><td>ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង</td><td>-</td></tr>
<tr><td colspan="4">ការចុះកិច្ចព្រមព្រៀងរវាងម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត គឺដើម្បីធានាថាភាគីពាក់ព័ន្ធទាំងអស់បានយល់ពីលក្ខខណ្ឌ និងវិសាលភាពការអនុវត្តគម្រោង តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ដំណើរការទូទាត់ ការតាមដាន និងត្រួតពិនិត្យ។</td></tr>
<tr><td>ដំណាក់កាលទី៥</td><td>ការភ្ជាប់បណ្តាញជូនគ្រួសារក្រីក្រ</td><td>ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត</td><td>-</td></tr>
<tr><td colspan="4">ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតត្រូវភ្ជាប់បណ្តាញដល់គ្រួសារក្រីក្រ ដែលមានលក្ខណសម្បត្តិទទួលបានឧបត្ថម្ភធន និងបានបង់ថវិកាបដិភាគតាមការព្រមព្រៀងគ្នា។</td></tr>
<tr><td>ដំណាក់កាលទី៦</td><td>ការផ្ទៀងផ្ទាត់តំណគ្រួសារក្រីក្រដែលបានភ្ជាប់រួចរាល់</td><td>ម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង</td><td>-</td></tr>
<tr><td colspan="4">បណ្តាញទឹកស្អាតដែលបានភ្ជាប់រួចរាល់ នឹងត្រូវផ្ទៀងផ្ទាត់ដោយម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោងយ៉ាងហោចណាស់ ៣០% នៃតំណថ្មី ដើម្បីធ្វើការទូទាត់ថវិកាដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដោយផ្អែកលើសូចនាករមួយចំនួនដូចខាងក្រោម៖<br>- បណ្តាញដែលបានភ្ជាប់ និងពិតជាគ្រួសារក្រីក្រដែលត្រូវទទួលបានការផ្តល់ឧបត្ថម្ភធន (ក្នុងបញ្ជីឈ្មោះ)<br>- ការភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្របានធ្វើរួចរាល់ និងជាតំណថ្មី (ពិនិត្យលើនាឡិកាទឹក)<br>- សម្ភារភ្ជាប់បណ្តាញបានដំឡើងទៅតាមកិច្ចព្រមព្រៀង និងស្តង់ដាបច្ចេកទេស<br>- គុណភាពទឹកស្របតាមស្តង់ដា។<br>បន្ទាប់ពីការចុះផ្ទៀងផ្ទាត់រួច ម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង នឹងជូនដំណឹងដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត អំពីលទ្ធផលដែលទទួលបាន ដោយបង្ហាញអំពីចំនួនតំណដែលបានដំឡើងត្រឹមត្រូវ និងអាចធ្វើការទូទាត់បាន ចំនួនតំណមិនត្រឹមត្រូវតាមកិច្ចព្រមព្រៀងដោយបញ្ជាក់ពីមូលហេតុ និងអនុសាសន៍ផ្សេងៗ ប្រសិនបើមាន។ បន្ទាប់ពីមានការព្រមព្រៀងគ្នាលើលទ្ធផលចុះផ្ទៀងផ្ទាត់ហើយ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតត្រូវស្នើសុំទូទាត់ថវិកាទៅម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង។</td></tr>
<tr><td>ដំណាក់កាលទី៧</td><td>ការទូទាត់ថវិកា</td><td>ម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង</td><td>-</td></tr>
<tr><td colspan="4">ការទូទាត់ថវិកាត្រូវធ្វើឡើងតាមលទ្ធផលដែលទទួលបាន។ ដំណាក់កាល និងរយៈពេលនៃការទូទាត់នឹងត្រូវកំណត់ក្នុងព្រមព្រៀងរវាងម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ ម្ចាស់ជំនួយ/ភ្នាក់ងារអនុវត្តគម្រោង នឹងទូទាត់ថវិកាឧបត្ថម្ភធនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនូវចំនួនតំណដែលបានដំឡើងត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់។ ការទូទាត់ថវិកានឹងអនុវត្តទៅតាមលក្ខខណ្ឌដូចការគណនាខាងក្រោម៖<br>- ថវិកាឧបត្ថម្ភធន = ចំនួនតំណបានភ្ជាប់រួចត្រឹមត្រូវ × ថ្លៃឧបត្ថម្ភធនក្នុង១តំណ (ដោយគិតបញ្ចូលថ្លៃទុយោបន្ថែម បើមាន)</td></tr>
</table>

## ឧបសម្ព័ន្ធ២៖ ទម្រង់ពាក្យស្នើសុំថវិកាឧបត្ថម្ភធន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំថវិកាឧបត្ថម្ភធនលើថ្លៃសិទ្ធិជាវទឹកស្អាតដល់គ្រួសារក្រីក្រ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................................ភេទ..........ជនជាតិ...................សញ្ជាតិ................ កើតថ្ងៃទី.................. ខែ................. ឆ្នាំ................... ទីលំនៅផ្ទះលេខ.............. ផ្លូវលេខ.................. ក្រុមទី................ ភូមិ.................... ឃុំ/សង្កាត់............................ ក្រុង/ស្រុក/ខណ្ឌ............................... រាជធានី/ខេត្ត...............................កាន់អត្តសញ្ញាណប័ណ្ណលេខ......................................... ទំនាក់ទំនង (ទូរស័ព្ទ ឬអ៊ីម៉ែល)........................................................ ជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅ (ឃុំ/ស្រុក/ខេត្ត) ..........................................................................................................................................។

ស្នើសុំថវិកាឧបត្ថម្ភធនលើសិទ្ធិជាវទឹកស្អាតដល់គ្រួសារក្រីក្រក្នុងតំបន់សេវាកម្មរបស់ ខ្ញុំបាទ/នាងខ្ញុំតាមរយៈ គម្រោង..............................................ដែលអនុវត្តដោយ ......................................................។

## ១. ព័ត៌មានទូទៅអំពីអាជីវកម្មទឹកស្អាត

| | | |
|---|---|---|
| ១. | កាលបរិច្ឆេទប្រកាសអនុញ្ញាត | |
| ២. | ចំនួនភូមិក្នុងប្រកាសអនុញ្ញាត | |
| ៣. | ចំនួនគ្រួសារសរុបក្នុងតំបន់សេវា | |
| ៤. | ចំនួនគ្រួសារក្រីក្រសរុបក្នុងតំបន់សេវា | |
| ៥. | ចំនួនភូមិដែលបានដាក់ទុយោរួចរាល់ | |
| ៦. | ចំនួនគ្រួសារដែលបានភ្ជាប់ទឹកស្អាត | |
| ៧. | ចំនួនគ្រួសារក្រីក្រក្នុងភូមិបានដាក់ទុយោរួចរាល់ | |
| ៨. | ថ្លៃលក់ទឹក | |
| ៩. | ថ្លៃសិទ្ធិជាវទឹកស្អាត | |

## ២. ព័ត៌មានអំពីហេដ្ឋារចនាសម្ព័ន្ធ

| | | | | | |
|---|---|---|---|---|---|
| ១០. ប្រភពទឹក | ☐ទន្លេ ☐ស្រះ ☐អណ្តូង ☐ផ្សេងៗ................................ | | | | |
| ១១. មធ្យោបាយផលិតកម្ម | ☐អាងប្រព្រឹត្តកម្ម ☐អាងស្តុក ☐អាងអាកាស ☐ម៉ូទ័រចែកចាយ | | | | |
| ១២. សមត្ថភាពផលិត (ម៣/ម៉ោង) | | | ចំនួនម៉ោងផលិត/ថ្ងៃ | | |
| ១៣. ប្រភេទទុយោ | | ប្រវែងសរុប | | មុខកាត់ចន្លោះពី | |
| | | ប្រវែងសរុប | | មុខកាត់ចន្លោះពី | |
| | | ប្រវែងសរុប | | មុខកាត់ចន្លោះពី | |
| | | ប្រវែងសរុប | | មុខកាត់ចន្លោះពី | |
| ១៤. ត្រួតពិនិត្យគុណភាពទឹក | ☐ រាល់៣ខែម្តង | | ☐ ភ្ជាប់លទ្ធផលមកជាមួយ | | |
| | ☐ ប្រចាំឆ្នាំ | | ☐ ភ្ជាប់លទ្ធផលមកជាមួយ | | |

| ១៥. សម្ភារភ្ជាប់បណ្តាញ | | ចំនួន | ថ្លៃ (ដុល្លារ) |
|---|---|---|---|
| នាឡិកាទឹក | ☐ | | |
| ក្លាប៉េ | ☐ | | |
| វ៉ាន់ចាក់សោរ | ☐ | | |
| វ៉ាន់បិទ/បើក | ☐ | | |
| កំលាំងពលកម្ម | ☐ | | |
| ប្រអប់នាឡិកាទឹក | ☐ | | |
| ទុយោ (ប្រភេទ...............) | ☐ | | |
| | | | |
| | | | |
| | | | |
| | | | |

## ៣. ព័ត៌មានលម្អិតអំពីតំបន់សេវាកម្ម(ប្រកាសអនុញ្ញាត)

១៦. ព័ត៌មានលម្អិតអំពីតំបន់សេវាកម្ម(ប្រកាសអនុញ្ញាត)៖

| ភូមិ | ឃុំ | មានបណ្តាញ ទុយោ ឬអត់? | ចំនួនគ្រួសារ | ចំនួនអតិថិជន សរុប | ស្នើសុំថវិកា ឧបត្ថម្ភធន? |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

| ភូមិ | ឃុំ | មានបណ្ដាញទុយោ ឬអត់? | ចំនួនគ្រួសារ | ចំនួនអតិថិជនសរុប | ស្នើសុំថវិកាឧបត្ថម្ភធន? |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ៤. ឆន្ទៈរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

| | |
|---|---|
| ១៧. មូលហេតុក្នុងការស្នើសុំថវិកាឧបត្ថម្ភធនដល់គ្រួសារក្រីក្រ | |
| ១៨. ការចូលរួមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ក្រៅពីថវិកាឧបត្ថម្ភធន | |
| ១៩. ខ្ញុំបាទ/នាងខ្ញុំ យល់ព្រមផ្ដល់ទិន្នន័យ ឬព័ត៌មានផ្សេងៗដែលចាំបាច់ក្នុងការតាមដានត្រួតពិនិត្យ និងក្នុងគោលបំណងសិក្សាវាយតម្លៃផ្សេងៗរបស់គម្រោង។ | ☐ |

**<u>ចំណាំ</u>** ៖ រាល់ព័ត៌មានទាំងអស់ដែលត្រូវបំពេញ គឺជាព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាព។

**ធ្វើនៅ.......................ថ្ងៃទី.........ខែ............ឆ្នាំ.............**

**ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត**

**ឈ្មោះ.................................**

**តួនាទី.................................**

បានឃើញ និងយល់ស្រប

ថ្ងៃទី......ខែ.............ឆ្នាំ...........

ឈ្មោះ.............................

**មេឃុំ/ចៅសង្កាត់**